ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

លេខ : ៣៤៩១ សជណ

ថ្ងៃអង្គារ ៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០២៤

**ជម្រាបមក**

**លោក សៅ វណ្ណសី**

**ប្រធានអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច**

**កម្មវត្ថុ** ៖ ស្តីពីសំណើសុំផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការកណ្តាលរបស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច។

**យោង** ៖
- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ៨៤០ សជណ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ២២៥៦ សជណ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ០៤១/២០២៤/ICSO ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ របស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានអង្គការថា ក្រសួងមហាផ្ទៃបានពិនិត្យនិងសម្រេចយល់ព្រមតាមសំណើរបស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ក្នុងការសម្រេចផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការកណ្តាលមកនៅផ្ទះលេខPA១២ ផ្លូវលេខ៣៦ ភូមិកាកាប សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់លេខ២០៨១/២៤ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ របស់សាលាសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ទន្ទឹមនេះ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ត្រូវធ្វើសកម្មភាពនិងបំពេញកាតព្វកិច្ចស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាននិងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមលោកប្រធានអង្គការជ្រាបជាព័ត៌មាននិងចាត់ចែងអនុវត្ត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ជ.រដ្ឋមន្ត្រី
**រដ្ឋលេខាធិការ**

**ប៊ី . សុភផាន**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានីភ្នំពេញ
- ឯកសារ កាលប្បវត្តិ